# ជំងឺជ្រូកត្រចៀកខៀវ

## (Porcine Reproductive and Respiratory Syndrome)

### តើអ្វីទៅជាជំងឺជ្រូកត្រចៀកខៀវ?

ជំងឺជ្រូកត្រចៀកខៀវ ឬ ជំងឺប្រដាប់ដង្ហើម និង ផលិតភាពបន្តពូជ (PRRS) ជាជំងឺដែលគេទើបរកឃើញដំបូងនៅ អាមេរិកខាងជើងនាឆ្នាំ ១៩៨៧ អឺរ៉ុប ឆ្នាំ ១៩៩០ បង្កឡើងដោយវីរុសប្រភេទ

– Family: Arteriviridae

– Genus: Arterivirus មាន ២ ស៊េរ៉ូទីប : European type and Americam type

សត្វទទួលជំងឺរួមមានជ្រូកគ្រប់វ័យ ទាំងជ្រូកមេ មេផើម កូនជ្រូក ជ្រូកបា និងជ្រូកសាច់ ។

វីរុសធ្វើឲ្យខូចខាតប្រព័ន្ធការពារខ្លួនបណ្ដាលឲ្យមេរោគផ្សេងៗជ្រៀតចូល ។ ជំងឺដែលមានការឆ្លងរាលដាលរាតត្បាតឆាប់រហ័ស និងខ្លាំងក្លាបណ្ដាលឲ្យមានអត្រាឈឺ ស្លាប់ និងរលូតកូនមានកម្រិតខ្ពស់។ជំងឺនេះច្រើនកើតនៅតាមកន្លែងចិញ្ចឹមដែលមានដង់ស៊ីតេជ្រូកខ្ពស់ ។

### ១. លក្ខណៈរបស់វីរុស

ជំងឺនេះបង្កឡើងដោយវីរុស ហើយវីរុសនេះអាចផ្លាស់ប្ដូរទម្រង់យ៉ាងឆាប់រហ័ស ។ វីរុសជំងឺជ្រូកត្រចៀកខៀវចូលចិត្តរស់នៅម៉ាក្រូហ្វាស ជាពិសេសចូលចិត្តរស់នៅម៉ាក្រូហ្វាសនៅសួត ។ នៅពេលដែលវីរុសបំបែកខ្លួនវាអាចសម្លាប់មីក្រូហ្វាស បន្ទាប់មកសារពាង្គកាយជ្រូកមិនអាចប្រឆាំងជាមួយការចម្លងជំងឺផ្សេងៗទៀតបានទេ ។ ក្នុងករណីដែលវីរុសមិនអាចសម្លាប់មីក្រូហ្វាស វាអាចរស់នៅក្នុងម៉ាក្រូហ្វាសបានរយៈពេលជាច្រើនខែ។

វីរុសអាចរស់បានរយៈពេល ៣៥ ថ្ងៃ នៅក្នុងឈាមជ្រូកដែលឆ្លងជំងឺ ៤–៥ ខែ នៅសីតុណ្ហភាព –៧០ អង្សាសេ ។

### ២. ការរាលដាល

កម្រិតរាលដាលខ្ពស់ បណ្ដាលឲ្យមានអត្រាឈឺ ស្លាប់ខ្ពស់ ។

តាមការស្រាវជ្រាវគេឃើញមានជំងឺនេះនៅគ្រប់តំបន់ ជាពិសេសនៅអាស៊ីភាគអគ្នេយ៍វៀតណាម ថៃឡង់ដ៍ ចិន។ បច្ចុប្បន្នជំងឺនេះបាននឹងកំពុងផ្ទុះឆ្លងរាលដាលនៅប្រទេសថៃឡង់ដ៍ សាធារណៈរដ្ឋប្រជាមានិតឡាវ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។ ហើយនៅព្រះរាជាណាចក្រកម្ពុជានាពេលថ្មីៗនេះ តាមរយៈការចុះពិនិត្យស្រាវជ្រាវ អង្កេត តាមដាន និងចុះយកសំណាកដើម្បីធ្វើវិភាគរោគ ជ្រូកមួយចំនួនមានវត្តមានអង់ទីគ័រជំងឺជ្រូកត្រចៀកខៀវ(ខេត្តកំពង់ឆ្នាំង កណ្ដាល កំពង់ចាម តាកែវ ព្រៃវែង បាត់ដំបង និងខេត្តកំពត)។

### ៣. ការចម្លង

- ចម្លងតាមការប៉ះពាល់ជាមួយនឹងជ្រូកឈឺ–សារធាតុដែលហូរចេញពីរាង្គកាយសត្វឈឺ
- ទឹកស្មែម
- ឧបករណ៍ សម្ភារៈ និងមធ្យោបាយដឹកជញ្ជូន
- ម្ជុលចាក់ថ្នាំ និង វ៉ាក់សាំង

– តាមរយៈទងសុកៈ វីរុសអាចឆ្លងទៅកូនជ្រូកនៅក្នុងរយៈពេលខែចុងក្រោយនៅក្នុងពោះមេ។ កូនជ្រូកដែលខ្សោយមានផ្ទុកបរិមាណវីរុសយ៉ាងច្រើននៅក្នុងឈាម (ត្រូវតែសម្លាប់ចោល)។






របៀបនៃការចម្លងមេរោគតាមរយៈការបង្កាត់ពូជ

## ៤. រោគសញ្ញា

ជំងឺនេះមានរោគសញ្ញាពីរផ្នែកដាច់ពីគ្នាច្បាស់លាស់ គឺការខូចខាតលើប្រព័ន្ធបន្តពូជ និងប្រព័ន្ធផ្លូវដង្ហើមនៅពេលដែលកសិដ្ឋានឆ្លងជំងឺនេះជាលើកដំបូង ប៉ុន្តែវានឹងពិបាកក្នុងការធ្វើរោគវិនិច្ឆ័យណាស់នៅពេលដែលការឆ្លងជំងឺនេះ វាមានរយៈពេលជាយូរមកហើយ ដើម្បីកំណត់រោគវិនិច្ឆ័យជំងឺឲ្យកាន់តែច្បាស់ត្រូវយកឈាមទៅវិភាគនៅមន្ទីរពិសោធន៍។

រោគសញ្ញានៅលើមេជ្រូក

- មានកំដៅឡើងចន្លោះ៣៩-៤០ អង្សាសេ សម្រាប់ប៉ុន្មានថ្ងៃដំបូងនៃការឈឺ
- មិនស៊ីចំណី និង មិនផឹកទឹក ក្នុងរយៈពេលខ្លីនឹងអាចអូសបន្លាយពី៧-១៤ ថ្ងៃ មានចំនួនពី ១០-១៥%
- រលូតកូនមានចំនួនច្រើនជាង ១០%
- កើតកូនមុនថ្ងៃកំណត់ (១០៨ ទៅ ១១២ ថ្ងៃ ) តាមធម្មតាវាត្រូវ ១១៤ ថ្ងៃ
- កូនកើតមកខ្សោយ មេអត់ទឹកដោះ នាំឲ្យអត្រាកូនងាប់មុនពេលផ្ដាច់ដោះកើនឡើង ៣០-៥០%
- កូនជ្រូកងាប់នៅក្នុងពោះហើយស្ងួតដែលអត្រាពី ២៥-៣៥% ។
- ពេលខ្លះត្រចៀកឡើងពណ៌ខៀវ
- ក្អក ដង្ហក់
- រលៀកដោះ
- មេផ្ដាច់ដោះមិនងាយរកឈ្មោល (២១-៣៥ថ្ងៃ)។





រោគសញ្ញានៅលើមេជ្រូកធើម









*កូនជ្រូករលូតងាប់ស្វិត*

**រោគសញ្ញា លើជ្រូកធា**

- មិនស៊ីចំណី
- សីតុណ្ហភាពក្នុងខ្លួនកម្តៅខ្ពស់
- ដំណើរស្ពឹកៗរឹងជើងមុខនិងក្រោយ
- បាត់បង់ចំណង់ផ្លូវភេទ
- គុណភាពផលិតថយចុះ (ចំនួនកូនបង្កាត់ក្នុងសំបុកតិច ខ្សោយ)



*រោគសញ្ញានៅលើជ្រូកបា*

- ផលិតផលស្ពែមថយចុះ

**រោគសញ្ញានៅលើកូនជ្រូកផ្តាច់ដោះ**

- រោគសញ្ញាលើផ្លូវដង្ហើម ១ ទៅ ៣សប្តាហ៍ បន្ទាប់ពីផ្តាច់ដោះ
- មិនស៊ីចំណី
- ក្តៅស្បែកឡើងពណ៌ក្រហម
- រលាកសួតធ្ងន់ធ្ងរជាមួយនឹងការក្អក និងពិបាកដកដង្ហើម ហូរទឹកភ្នែក
- ត្រចៀកឡើងពណ៌ខៀវ
- ទម្រង់រាង្គរបស់កូនជ្រូកមិនល្អ : ស្គមកំព្រឹង រោមមានសភាពរឹង ការលូតលាស់ប្រចាំថ្ងៃធ្លាក់ចុះរហូតដល់ ៨៥%
- លាមកភាគពណ៌បៃតងចាស់
- អត្រាស្លាប់ខ្ពស់បំផុត បើទោះជាមានការព្យាបាលក៏ដោយ (១០–២៥%) ។

**រោគសញ្ញានៅលើជ្រូកចិញ្ចឹមយកសាច់**





ស្បែកឡើងក្រហម





រោគសញ្ញាលើកូនជ្រូកនៅផ្តាច់ដោះ

ជំងឺនេះ កម្រកើតណាស់លើជ្រូកបំប៉នយកសាច់ ។ រោគសញ្ញាដែលសង្កេតឃើញមានដូចខាងក្រោម :

- រលាកសួត ក្អក និងពិបាកដកដង្ហើម
- ភ្នែកក្រហម មានពពិចភ្នែក
- ពេលខ្លះត្រចៀកឡើងពណ៌ខៀវ
- អត្រាស្លាប់កើនឡើង
-



មានស្នាមជាំឈាមនៅលើខ្លួន



ត្រចៀកឡើងពណ៌ស្វាយ



រោគសញ្ញាលើជ្រូកនៅពេលបំប៉នយកសាច់



រោគសញ្ញានៅលើថ្ពាល់ដែលបំប៉នយកសាច់





ត្រចៀកពណ៌ស្វាយ



ស្លាកស្នាមដែលគេអង្កេតឃើញនៅពេលធ្វើការវះកាត់



ត្រចៀកពណ៌ក្រហម





នៅជុំវិញបេះដូង ដែលមានលក្ខណៈជាសរសៃៗ

- ជាទូទៅ ប្រសិនបើចង់យកសួតចេញមកក្រៅ គឺផ្នែកមួយរបស់សួតភ្ជាប់ទៅនឹងខ្លួនសត្វ (Pleuresia) ស្លាកស្នាមដំបៅ គឺវាអាស្រ័យផងដែរទៅលើជំងឺផ្សេងៗទៀត ដែលមានវត្តមាននៅក្នុងកសិដ្ឋាន ។

**៥. ការព្យាបាល**

- មិនអាចព្យាបាលបានទេ ដោយសារតែ





រោគសញ្ញាដែលគេអង្កេតឃើញនៅពេលវះពិនិត្យ





ស្នាមដំបៅដែលសង្កេតឃើញនៅពេលធ្វើការវះកាត់

វាបង្កឡើងដោយវីរុស ប៉ុន្តែបើយើងប្រើអង់ទីប៊ីយ៉ូទិចក្នុងការទប់ស្កាត់ ការឆ្លងធ្ងន់ធ្ងរបាន (ទប់ទល់នឹងមេរោគឱកាសនិយម)

– ការឆ្លងធ្ងន់ធ្ងរ វាអាស្រ័យលើមេរោគផ្សេងៗដែលវិលវល់នៅក្នុងកសិដ្ឋានដូចជា:

*Streptococcus*

*Haemophilu*

*Actinobacillus*

*Pasteurella*

*Mycoplasma*

ដូចនេះទោះបីជាមិនអាចព្យាបាលជំងឺនេះបាន (*PRRS*) តែយើងត្រូវប្រើអង់ទីប៊ីយ៉ូទិចសម្រាប់ការពារជំងឺឆ្លងធ្ងន់ធ្ងរ។

## ៦. ការការពារការឆ្លងធ្ងន់ធ្ងរ

ប្រើ Florfenicol សម្រាប់រយៈពេល ៣ សប្តាហ៍ ចាប់តាំងពីពេលដែលកូនជ្រូកចាប់ផ្តើមស៊ីចំណី

– ប្រើ Tylocycline សម្រាប់រយៈពេល ១ សប្តាហ៍ នៅពេលដែលយើងផ្លាស់ប្តូរជ្រូកពីអាគារមួយទៅអាគារមួយទៀត ពីព្រោះភាពតានតឹង (ស្រ្តេស) វាធ្វើឲ្យជ្រូកងាយនឹងទទួលរងការឆ្លងជំងឺ

– ប្រើ Tetravit ចំពោះមេជ្រូក សម្រាប់រយៈពេល ៣ សប្តាហ៍ ហើយប្រើសារជាថ្មីទៀតបើទិន្នផលចិញ្ចឹមធ្លាក់ចុះ។

## ៧. ការចាក់ថ្នាំបង្ការ (វ៉ាក់សាំង)

នៅពេលបច្ចុប្បន្ន ការចាក់វ៉ាក់សាំងមិនអនុញ្ញាតឲ្យប្រើទេ ពីព្រោះ

- យើងមិនដឹងតើប្រភេទ Strain អ្វីដែលមាននៅកម្ពុជា
- វីរុសអាចប្រែប្រួលយ៉ាងរហ័ស
- ការប្រើវ៉ាក់សាំងរស់ អាចបង្កើនហានិភ័យនៃការឆ្លងរាលដាលជំងឺ ។

## ៨. វិធានការបន្ទាន់ឆ្លើយតបនឹងវត្តមានជំងឺជ្រូកត្រចៀកខៀវនៅកម្ពុជា:

បច្ចុប្បន្នក្នុងករណីដែលកំពុងផ្ទុះជំងឺត្រចៀកខៀវជ្រូក គប្បីអ្នកចិញ្ចឹមជ្រូក និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវតែព្យាយាមៈ

ក/ កាត់ផ្ដាច់ ឬ លុបបំបាត់មេកានិកចម្លងជំងឺដោយ ៖

- ទប់ស្កាត់ការនាំចូលសត្វឈឺ មនុស្ស ឬ សម្ភារៈផ្សេងៗពីកន្លែងមានផ្ទុះជងឺសត្វ
- សម្លាប់សត្វឈឺ សត្វផ្ទុកជំងឺ បាញ់ថ្នាំសម្លាប់មេរោគ
- ធ្វើចត្តាឡីស័ក ។

ខ/ បង្កើនភាពធន់របស់សត្វ ៖

ការថែទាំសុខភាព

ផ្ដល់ចំណីអាហារ ទឹកគ្រប់គ្រាន់

ជីវសុវត្ថិភាព អនាម័យ ។

គ/ តាមដាន ស្រាវជ្រាវ អង្កេត ផ្សព្វផ្សាយ

- តាមដានសុខភាពសត្វជាប្រចាំ ដើម្បីចាត់វិធានការបសុពេទ្យឲ្យបានទាន់ពេលវេលា
- ចុះអង្កេត ស្រាវជ្រាវ តាមដានជំងឺ យកវត្ថុវិភាគ ធ្វើតេស្ដ រកប្រភេទមេរោគ
- ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល ។

ឯកសារយោងៈ

ឯកសារជំនួយស្មារតីស្ដីពីស្ថានភាពជំងឺប្រដាប់ដង្ហើម និងផលិតភាពបន្ដពូជជ្រូក ដោយបណ្ឌិត សួន សុធឿន
បទបង្ហាញរបស់លោក ហ៊ល ដារុន ស្ដីពីជំងឺត្រចៀកខៀវជ្រូកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
បទបង្ហាញរបស់លោក ពេជ ប៉េដា ស្ដីពីជំងឺជ្រូកត្រចៀកខៀវ
បទបង្ហាញរបស់លោក ម៉ក់ ចាន់ថុល ស្ដីពីជំងឺជ្រូកត្រចៀកខៀវ
គម្រោងចិញ្ចឹមសត្វកម្ពុជាសហគមន៍អឺរ៉ុបកម្មវិធីបណ្ដុះបណ្ដាលភ្នាក់ងារសុខភាពសត្វភូមិឡើងវិញ
The MERCK VETERINARY MANUAL
htt://www.thepigsite.com/diseaseinfo/97/porcine-reproductive-respiratory-syndrome-prrs
សេចក្ដីប្រកាសលេខ ០៨ ស.ប្រ.ក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១០ ស្ដីពីវិធានការទប់ស្កាត់ការនាំជ្រូកចូលដោយខុសច្បាប់
សេចក្ដីណែនាំស្ដីពីការពង្រឹងការត្រួតពិនិត្យជំងឺឆ្លងជ្រូករបស់ ន.ផ.ប លេខ ១៣៨២ ផ.ប
របាយការណ៍ស្ដីពីជំងឺត្រចៀកខៀវជ្រូកនៅប្រទេសជិតខាង និងនៅព្រះរាជាណាចក្រកម្ពុជារបស់ន.ផ.ប ។